គណនេយ្យភាពសង្គម
នៅរដ្ឋបាលថ្នាក់ក្រោមជាតិ

# ករណីសិក្សា

## ប្រសិទ្ធភាពការងារគណនេយ្យភាពសង្គមរបស់ មណ្ឌលសុខភាពចន្លាស់ដៃ







គជអប NCDD

Australian Aid

THE WORLD BANK

# ករណីសិក្សា

## ប្រសិទ្ធភាពការងារគណនេយ្យភាពសង្គមរបស់មណ្ឌលសុខភាពចន្លាស់ដៃ

តាមរយៈគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ការផ្តល់សេវា និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ប្រកបដោយបរិយាប័ន្ន សមធម៌ និងយុត្តិធម៌ ជាចំណុចអាទិភាពមួយដែលរាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់ និងជំរុញទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ រាជរដ្ឋាភិបាលបានបន្តអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី២ (២០១៩-២០២៣) ដែលបានអនុម័ត និងដាក់ឱ្យអនុវត្តនៅខែវិច្ឆិកា ឆ្នាំ២០១៩ ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាពក្នុងការផ្តល់សេវារបស់រដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាពជូនប្រជាពលរដ្ឋនៅមូលដ្ឋាននិងផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋសហគមន៍មូលដ្ឋាន ក្នុងការចូលរួមពង្រឹងការចាត់ចែងការប្រើប្រាស់ថវិកា និងការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន តាមរយៈការលើកកម្ពស់នូវភាពងាយទទួលបានព័ត៌មាន ការចូលរួមពិនិត្យតាមដានលើការងារថវិកា និងការបំពេញការងាររបស់អង្គភាពផ្តល់សេវាទាំងបី។ ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម ភាគីរដ្ឋជា "ផ្នែកផ្គត់ផ្គង់" (តំណាងក្រសួង/ស្ថាប័នពាក់ព័ន្ធ) និងប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល "ផ្នែកតម្រូវការ" បានទទួលការគាំទ្រថវិកាមូលនិធិបរធនបាលកិច្ច គ្រប់គ្រងដោយធនាគារពិភពលោក។

មណ្ឌលសុខភាពចន្លាស់ដៃ មានទីតាំងស្ថិតនៅក្នុងឃុំចន្លាស់ដៃ ស្រុកក្រឡាញ់ ខេត្តសៀមរាប។ លោក កុំ សារ៉ូ ប្រធានមណ្ឌលសុខភាពចន្លាស់ដៃបានមានប្រសាសន៍បញ្ជាក់អំពីដំណើរការរបស់មណ្ឌលសុខភាពថា មណ្ឌលសុខភាពចន្លាស់ដៃបានចាប់ផ្តើមដំណើរការក្នុងការផ្តល់សេវាសុខាភិបាលជូនដល់ប្រជាពលរដ្ឋចាប់តាំងពីឆ្នាំ២០០៧មក។

ការអនុវត្តការងារគណនេយ្យភាពសង្គមរបស់មណ្ឌលសុខភាពចន្លាស់ដៃបានចាប់ផ្តើមអនុវត្តចាប់ពីឆ្នាំ២០១៦ ដោយមានភាពជាដៃគូក្នុងការអនុវត្តសកម្មភាពគណនេយ្យភាពសង្គមផ្នែកតម្រូវការដោយអង្គការទស្សនៈពិភពលោក។



លោក កុំ សារ៉ូ ប្រធានមណ្ឌលសុខភាពចន្លាស់ដៃ។
រូបភាព៖ លោក អ៊ិត សំអាត

បច្ចុប្បន្ននេះ មណ្ឌលសុខភាពចន្លាស់ដៃមានបុគ្គលិកក្របខ័ណ្ឌចំនួន០៧ នាក់ ក្នុងនោះគិលានុបដ្ឋាយិកាមធ្យមចំនួន០៤ នាក់ និងបុគ្គលិកឆ្មបចំនួន០៣ នាក់។ ក្នុងនោះមណ្ឌលសុខភាពនេះកំពុងផ្តល់សេវាជូនប្រជាពលរដ្ឋដោយគ្រប់ដណ្តប់លើភូមិចំនួន១២ នៃឃុំចន្លាស់ដៃ ដែលមានប្រជាជនសរុបចំនួន១០.១០១នាក់ ជាមធ្យមអ្នកជំងឺបានមកទទួលសេវាសុខាភិបាលនៅមណ្ឌលសុខភាពចំនួនពី៨០០ នាក់ទៅ៩០០ នាក់ ក្នុងមួយខែៗ។ មណ្ឌលសុខភាពមានសកម្មភាពអាទិភាពនៅក្នុងផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ដែលផែនការនេះមានគណៈកម្មាធិការមួយដើម្បីធ្វើការត្រួតពិនិត្យតាមដានវឌ្ឍនភាព និងបញ្ហាប្រឈមដោយមានសមាសភាពដូចជា ក្រុមប្រឹក្សាឃុំ មេប៉ុស្តិ៍រដ្ឋបាល នាយកសាលា ប្រធានមណ្ឌលសុខភាព និងតំណាងប្រជាពលរដ្ឋ។ គណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម បានធ្វើការប្រជុំរបស់ខ្លួនយ៉ាងទៀងទាត់ រយៈពេល៣ខែម្តង។

លោក កុំ សារ៉ូ បានបន្តទៀតថាមុនពេលការអនុវត្តការងារគណនេយ្យភាពសង្គមនៅក្នុងមណ្ឌលសុខភាពចន្លាស់ដៃ គឺឃើញថាការបំពេញការងាររបស់បុគ្គលិកមានការធ្វេសប្រហែស អត្តចរិកក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋមានភាពខ្វះចន្លោះ ចំណែកឯប្រជាពលរដ្ឋមិនហ៊ានបញ្ចេញនូវមតិយោបល់ ឬធ្វើការស្នើសុំពីតម្រូវការរបស់ពួកគាត់មកដល់បុគ្គលិកមណ្ឌលសុខភាពឡើយ។ ក្រោយពេលការអនុវត្តការងារគណនេយ្យភាពសង្គម យើងឃើញថាមានការផ្លាស់ប្តូរជាវិជ្ជមានច្រើនតាមរយៈការដាក់ពិន្ទុពីចំណុចខ្វះខាតនៅក្នុងមណ្ឌលសុខភាព ធ្វើឱ្យបុគ្គលិកទាំងអស់បានកែតម្រូវនៅចំណុចខ្វះខាតទាំងនោះ ដូចជាការផ្តល់សេវាមានភាពរួសរាយរាក់ទាក់ ការមកបំពេញការងារតាមពេលវេលាដែលក្រសួងសុខាភិបាលបានកំណត់ បុគ្គលិកបំពេញការងារបានល្អជាងមុនប្រកបដោយក្រមសីលធម៌និងវិជ្ជាជីវៈ និងការស្លៀកពាក់ឯកសណ្ឋានបានត្រឹមត្រូវ។ ចំណុចដែលខ្ញុំចាប់អារម្មណ៍ខ្លាំងគឺ ស្ត្រីមានផ្ទៃពោះគាត់មកពិនិត្យផ្ទៃពោះមុនសម្រាលទៅតាមការកំណត់របស់គ្រូពេទ្យ។ នៅពេលដែលគាត់មានបញ្ហាផ្សេងៗ គាត់តែងតែមកពិគ្រោះយោបល់ និងទទួលបានការណែនាំពីក្រុមគ្រូពេទ្យនៅទីនេះយ៉ាងច្បាស់លាស់សិនមុននឹងគាត់ទៅកន្លែងផ្សេង។ ជារួមប្រជាពលរដ្ឋដែលមកទទួលសេវាមានការកើនឡើង ដោយសារប្រជាពលរដ្ឋមានទំនុកចិត្ត និងពេញចិត្តទៅលើគុណភាព ការផ្តល់សេវាដ៏ល្អ ពីសំណាក់គ្រូពេទ្យរបស់មណ្ឌលសុខភាព។

លោក លឿង សិរាវុធ ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិក្រឡាញ់មានប្រសាសន៍ថា ការិយាល័យស្រុកប្រតិបត្តិ បានចូលរួមអភិវឌ្ឍន៍ និងជំរុញការងារគណនេយ្យភាពសង្គមដោយបានចូលរួមវគ្គបណ្តុះបណ្តាលធនធានមនុស្ស និងបានបណ្តុះបណ្តាលបន្តដល់បុគ្គលិកមណ្ឌលសុខភាព ប្រធានមណ្ឌលសុខភាពអំពីការងារគណនេយ្យភាពសង្គម ផ្តល់ការគាំទ្រទៅលើផ្នែកបច្ចេកទេស ឱ្យគាត់យល់ទៅលើការផ្តល់សេវា ស្របទៅនឹងកម្មវិធីជាតិ និងគោលនយោបាយរបស់រដ្ឋាភិបាល និងផ្តល់ការគាំទ្រទៅផ្នែកឱសថ ក៏ដូចជាបរិក្ខារផ្សេងៗរបស់មណ្ឌលសុខភាព។



លោក លឿង សិរាវុធ ប្រធានការិយាល័យសុខាភិបាល
ស្រុកប្រតិបត្តិក្រឡាញ់ រូបភាព៖ លោក អ៊ិត សំអាត

ជាក់ស្តែងយើងបានធ្វើការខិតខំស្នើសុំបុគ្គលិកបន្ថែម ពីមុនមានបុគ្គលិកមានតែ០៤នាក់ សព្វថ្ងៃមាន០៧នាក់។ លោកបានបង្ហាញពីការពេញចិត្តចំពោះការងារគ្រប់គ្រងរបស់មណ្ឌលសុខភាពដែលបានរៀបចំការផ្សព្វផ្សាយព័ត៌មានក៏ដូចជាមានកិច្ចប្រជុំផ្សព្វផ្សាយព័ត៌មាននានា ព័ត៌មានថវិកាមណ្ឌលសុខភាព កិច្ចប្រជុំដាក់ពិន្ទុ ត្រួតពិនិត្យតាមដានវាយតម្លៃ ដោយមានគណៈកម្មាធិការ មន្ត្រីបង្គោលគណនេយ្យភាពសង្គមឃុំ សង្កាត់ ក៏ដូចជាប្រជាពលរដ្ឋបានចូលរួម។

អ្នកស្រី អុយ សារុំ ប្រជាពលរដ្ឋ រស់នៅឃុំចន្លាស់ដៃ ស្រុកក្រឡាញ់ បានបង្ហាញពីការពេញចិត្តក្នុងការមកទទួលសេវានៅមណ្ឌលសុខភាព ដោយអ្នកស្រីបានមានប្រសាសន៍ថាទាំងទឹកមុខរីករាយថា "នាងខ្ញុំមានការពេញចិត្តក្នុងការមកទទួលសេវានៅទីនេះ ដោយសារគ្រូពេទ្យនៅទីនេះមានភាពរួសរាយរាក់ទាក់ និងមានប្រសិទ្ធភាពក្នុងការព្យាបាលដោយមិនមានភាពរើសអើងអ្នកជំងឺឡើយ"។



អ្នកស្រី អុយ សារុំ ប្រជាពលរដ្ឋ រស់នៅស្រុកក្រឡាញ់ ។
រូបភាព៖ លោក ម៉ន សុថារិៈ

ចំពោះទិសដៅបន្តក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមក្នុងមណ្ឌលសុខភាពលោកប្រធានមណ្ឌលសុខភាពបានលើកឡើងយ៉ាងមុតមាំថា លោកនឹងព្យាយាមពង្រឹងលើការផ្តល់សេវា និងការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋបន្ថែមទៀត ដោយចាត់តាំងបុគ្គលិកមណ្ឌលសុខភាពជួយពន្យល់បង្ហាញពីផ្ទាំងព័ត៌មានរបស់មណ្ឌលសុខភាព ដើម្បីឱ្យប្រជាពលរដ្ឋយល់ដឹងពីសិទ្ធិ និងស្តង់ដាការបំពេញការងារ ក៏ដូចជាព័ត៌មានថវិការបស់មណ្ឌលសុខភាព។ ទន្ទឹមនឹងនេះ លោកក៏សុំណូមពរដល់អ្នកពាក់ព័ន្ធ បន្តចែករំលែកនូវបទពិសោធន៍ល្អៗ និងគំនិតថ្មីៗដល់ថ្នាក់ក្រោមជាតិ និងស្នើសុំឱ្យមានការរៀបចំទស្សនកិច្ចសិក្សា ដើម្បីធ្វើការផ្លាស់ប្តូរនូវបទពិសោធន៍រវាងខេត្តមួយទៅខេត្តមួយ ដើម្បីសិក្សារៀនសូត្រ និងយកមេរៀនបទពិសោធន៍ល្អៗទាំងនោះមកអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ការផ្សារភ្ជាប់រវាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ បានផ្តល់ឱកាសដល់ប្រជាពលរដ្ឋសម្តែងនូវមតិយោបល់ និងចូលរួមតាមដានការបំពេញការងាររបស់មន្ត្រី និងបុគ្គលិកអង្គភាពផ្តល់សេវានៅមូលដ្ឋាន ព្រមទាំងបានធ្វើឱ្យប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាននៃមណ្ឌលសុខភាពចន្លាស់ដៃ មានភាពពេញចិត្ត ទំនុកចិត្តក្នុងការមកទទួលសេវានៅមណ្ឌលសុខភាព។ ទាំងនេះជាភាពជោគជ័យក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមនៅតាមមណ្ឌលសុខភាព។

“មានការងារគណនេយ្យភាពសង្គមនាំឱ្យប្រជាពលរដ្ឋទទួលបាននូវព័ត៌មាន និងមានភាពជឿជាក់ក្នុងការមកទទួលសេវា”







